


# ភាពនិមិត្តរបស់ក្មេងស្រី

## ឈ្មោះ យូនីធី

និមិត្តចុងក្រោយរបស់ក្មេងស្រី មកពីប្រទេស

ឥណ្ឌា ឈ្មោះ **នាងយូនីធី**

(ចេញពីផ្នែកនៃភ្លើងផុសផុលនៃព្រះវិញ្ញាណនៅឯក្រុងស៊ីឡុង)

[PDF] [DOC] [MP3] [Vido of Unity]WMV [Video:AVI Regarding Shillong Revival]
[Youtube] [Swedish]

**ថ្ងៃដែលខ្ញុំនិមិត្តឃើញព្រះយេស៊ូ គឺនៅថ្ងៃប្រកបកម្មវិធីយុវជនថ្ងៃអាទិត្យនៅថ្ងៃទី ៩ ខែមិនា ឆ្នាំ ២០០៦។**

**ព្រះយេស៊ូមានបន្ទូលប្រាប់ខ្ញុំនូវការបីយ៉ាង : ១) ការដេកលក់របស់ពួកបរិសុទ្ធ ២) ការគ្រប់គ្រងរបស់សត្វតិរច្ឆាន ៣) ការកាត់ទោសរបស់ព្រះជាម្ចាស់**



ពួកបរិសុទ្ធ ដែលធ្វើតាមបំណងព្រះហរទ័យព្រះ ហើយបានដេកលក់ទៅ ត្រូវបានលើកឡើងនៅកន្លែងដែលព្រះយេស៊ូ លេចមកអោយឃើញនៅពេលថ្ងៃត្រង់នៅអាកាស។

ទ្រង់លើកពួកអ្នកនៅលើផែនដី ដែលធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះ។ ពួកអ្នកដែលស្មោះត្រង់ដែលនៅ ក្នុងផ្លូវត្រូវបានលើកឡើងទៅលើពពកផងដែរ នៅក្នុងនិមិត្តរបស់ខ្ញុំនោះ។



ក្រោយពីនិមិត្ត ខ្ញុំបានឃើញទេវតាប្រយុទ្ធជាមួយនឹងនាគមួយដែលមានលេខ ៦៦៦។ វាត្រូវទទួលបរាជ័យ ហើយគ្មានកន្លែងណាសំរាប់វានៅឯស្ថានសួគ៌ ដូចនេះវាត្រូវទំលាក់ទៅលើផែនដី។

នាគនោះវានិយាយឡើងថា វានឹងគ្រប់គ្រងលើផែនដី ជាច្រើនឆ្នាំ។

វាក៏រត់ចេញទៅ ហើយមានសត្វតិរច្ឆានចេញមកមានក្បាល១០និងស្នែងប្រាំពីរ។ វាពាក់មកុដនៅលើក្បាលរបស់វាដែលមានឈ្មោះថាបណ្តាសា សរសេរនៅលើមកុដនោះ។

*អ្នកប្រកាស: តើវាមានរូបរាងដូចមនុស្សដែរឬទេ?* វាមានសណ្ឋានដូចមនុស្ស ប៉ុន្តែមើលទៅគួឱ្យខ្លាចមែនណាស់។ ខ្ញុំបានឃើញរាជរបស់វាសូម្បីតែអង្ករនិងលុយ ក៏មានសំគាល់និងត្រារបស់វាដែរ។ មនុស្សដែលជឿលើវា មានសំគាល់លេខ ៦៦៦ នៅលើពួកគេ។




*អ្នកប្រកាស: វាបោះត្រាលេខ ៦៦៦ នៅលើមុខទំនិញទាំអស់ឬ? ចុះតើមានអ្វីកើតឡើងចំពោះអ្នកដែលជឿលើព្រះយេស៊ូ?*



អ្នកដែលជឿលើព្រះយេស៊ូ នៅពេលនោះត្រូវគេធ្វើទុក្ខបុកម្នេញយ៉ាងធ្ងន់ធ្ងរដោយធ្វើទោសកាត់ក្បាល។ សាច់របស់គេត្រូវឆ្កួតទាំងរស់ ភ្នែករបស់គេត្រូវខ្វេះចេញ។ បំពង់កគេកាត់ដាច់ហើយដាក់ក្នុងខ្ទះធំ។

ពេលព្រះយេស៊ូ យាងមកផែនដីម្តងទៀត, ព្រះអង្គយាងខាងស្តាំនៅ លើអាកាសនៃផែនដី។ ពេលនាគ ដែលមានលេខ ៦៦៦ បានឃើញសិរីរុងរឿងរបស់ព្រះអង្គ នាគនោះមិនអាចទ្រាំទ្របាន ហើយរត់គេចខ្លួនបាត់ទៅ។ ពេលនោះអ្នកដែលស្លាប់ គឺអ្នកដែលដេកលក់បានភ្ញាក់ឡើងពីផ្នូររបស់គេ។

ទេវតាក៏ផ្លុំត្រែរបស់គេ ហើយអ្នកស្លាប់ទាំងអស់រស់ឡើងវិញចេញពីផ្នូររបស់គេ ដើម្បីទទួលការកាត់ទោសក្នុងថ្ងៃរបស់ព្រះអង្គម្ចាស់។



*អ្នកប្រកាស: អស្ចារ្យណាស់, អស្ចារ្យណាស់, មានអ្វីទៀតទេ កញ្ញាយូនីធី?*



រួចមកព្រះយេស៊ូ បានញែកពពែដាក់ទៅខាងឆ្វេង ហើយញែកចៀមដាក់ខាងស្តាំព្រះអង្គ។ ពពែទាំងនោះ គឺជាអស់អ្នកដែលមិនព្រមធ្វើតាមបំណងព្រះហឫទ័យព្រះអង្គ និងអ្នកដែលមានសំគាល់ ៦៦៦។ អ្នកនៅខាងស្តាំគឺជាកូនចៀម។ គេមានសំគាល់ឈើឆ្កាង ហើយនិងជាអ្នកដែកធ្វើតាមបំណងព្រះហរទ័យព្រះយេស៊ូ។

ព្រះអង្គបានកាត់ទោសគេម្នាក់ៗហើយដាក់តាមក្រុម, ពពែនិងចៀម។ ហើយម្នាក់ៗគឺកាត់ទោសនៅចំពោះព្រះជាម្ចាស់។ ហើយអំពើបាបរបស់គេម្នាក់ៗបានមើលឃើញតាមកញ្ចក់ទូរទស្សន៍។



ព្រះអង្គមានបន្ទូលសួរថា" ពេលគេធ្វើទីបន្ទាល់ពីព្រះដល់អ្នក តើអ្នកព្រមជឿ និងលន់តួបាបឬទេ? បើគេឆ្លើយថា "ទេ" ពួកគេត្រូវបោះចូលទៅបឹងភ្លើង។

ខ្ញុំបានឃើញអ្នក ដែលត្រូវបោះចូលទៅក្នុងបឹងភ្លើង ធ្លាក់ចូលទៅក្នុងរណ្ដៅដែលគ្មានបញ្ចប់។

ពួកគេធ្លាក់ចូលទៅក្នុងរណ្ដៅ ហើយប៉ឹងទៅរកទីកន្លែងគ្មានបញ្ចប់។ មានអណ្ដាតភ្លើងឆេះយ៉ាងក្ដៅ។ ពួកគេស្រែកយំ ហើយសង្កៀតធ្មេញ ដោយអង្វរព្រះយេស៊ូសុំមេត្តាករុណា។

ខ្ញុំក៏ឃើញកន្លែងមួយពេញទៅដោយដង្កូវ មានពស់ធំៗជាច្រើន និង ភ្លើងនរក។ ខ្ញុំឃើញមនុស្សនៅទីនោះដែរ។ ដង្កូវនឹងចូលតាមរន្ធច្រមុះម្ខាងហើយចេញតាមរន្ធច្រមុះម្ខាងទៀត។ ខ្ញុំបានឃើញដង្កូវមួយហ្វូងនៅលើថ្ពាល់មនុស្សទាំងនោះ។ ខ្ញុំបានឃើញពស់រុំព័ទ្ធជុំវិញខ្លួនគេ ហើយដង្កូវលូនពីលើខ្លួនគេ។

**ការលន់តួបាបអាចមាននៅផែនដី តែប៉ុណ្ណោះ គឺមិនអាចលន់តួបាបក្រោយពេលស្លាប់នោះ ឡើយ។**

## អ្នកប្រកាស : កញ្ញាឃុននីធី តើមានអ្វីកើតឡើងបន្ទាប់ពីនោះទៀត ?

ព្រះយេស៊ូ មានបន្ទូលថា ឥឡូវនេះគឺជា ពេលវេលាសំរាប់អ្នកកែប្រែអំពើបាប។ នៅក្នុងការកែប្រែចិត្តអ្នកនឹងទទួលបាន ការសង្គ្រោះ។ ព្រះយេស៊ូផ្ដល់ពេលឱ្យ យើងប្រែចិត្ត ពីព្រោះព្រះអង្គស្រលាញ់យើង។

## អ្នកប្រកាស : កញ្ញាឃុននីធី តើមានអ្វីទៀតទេ? ចាំនិមិត្តនោះគឺចប់ប៉ុណ្ណឹង

## និមិត្តមួយទៀតនៅក្នុងប្រទេសអូស្ត្រាលី ដោយភ្លើងនៃការផុសផុល



*អ្នកប្រកាស ៖ តើនៅទីកន្លែងណានៃប្រទេសអូស្ត្រលី, នៅទីក្រុងមួយណា?កញ្ញាយូនីធី ហាក់បីដូចជាមិនស្គាល់ តើទីក្រុងមួយណា ដែលបានឃើញ នៅក្នុងនិមិត្តរបស់នាង ឡើយ*

ខ្ញុំបានជួបព្រះយេស៊ូ នៅថ្ងៃអាទិត្យ ហើយព្រះអង្គបានបង្ហាញអោយខ្ញុំឃើញ នូវការអស្ចារ្យមួយចំនួន។ ព្រះយេស៊ូ បាននាំខ្ញុំទៅកាន់ប្រទេសអូស្ត្រាលី ជាកន្លែងដែលខ្ញុំបានជួប មិត្តភ័ក្តចំនួន ៤ នាក់ គឺ យ៉ូហាន, ខេនី, ម៉ាកូស, និង ម៉ារី។ ខ្ញុំបានឃើញមនុស្សជាច្រើន គេសប្បាយរីករាយ រាំសប្បាយ និង ច្រៀង។ ពួកគេបានទទួលភ្លើងនៃការផុសផុល។ ខ្ញុំបានច្រៀង រាំ និង សប្បាយជាមួយពួកគេ ពីព្រោះព្រះយេស៊ូបានបង្ហូរអស់ទាំងភ្លើងផុសផុលនៅក្នុងប្រទេសអូស្ត្រាលី។ នៅព្រះវិហារឯប្រទេសអូស្ត្រាលី ខ្ញុំបានឃើញទេវតានៅក្នុងនិងនៅខាងក្រៅព្រះវិហារ។ ទេវតាទាំងនោះកំពុងតែហោះជុំវិញជារង្វង់។ ទេវតា បានបន្លឺសំឡេងត្រែ ហើយបន្លឺសំឡេងនៃការសរសើរ និងអរព្រះគុណដល់ព្រះយេស៊ូ។ រួចមកព្រះយេស៊ូមានបន្ទូលថា ទ្រង់នឹងនាំខ្ញុំទៅកាន់កន្លែងដដែល ហើយយើងនឹងជួបគ្នាម្តងទៀតនៅថ្ងៃណាមួយ។

**(ចប់ខ្សែវីដេអូ)**